រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក សាមីជន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៥ :** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ១៩ អនក្រ.បក
## ស្ដីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស
## ស្ដីពីកិច្ចការព្រំដែន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋា ភិបាល ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលជំនួសអោយព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១៩ ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩៥ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅ :

**១-សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ :** ប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ចំរើន ជាតិ** មេបញ្ជាការកងការពារព្រំដែន នៃក្រសួងការពារជាតិ អនុប្រធាន

៣-ឧត្តមសេនីយ៍ត្រី **រស់គីមសាន** នាយក នាយកដ្ឋានភូមិសាស្ត្រនៃក្រសួងការពារជាតិ សមាជិក

៤-ឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្ត កំពង់ចាម សមាជិក

៥-ឯកឧត្តម **ឡូយ សុផាត** អភិបាលខេត្ត ស្វាយរៀង សមាជិក

៦-ឯកឧត្តម **ទេព នន្ទរី** អភិបាលខេត្ត ព្រៃវែង សមាជិក

៧-ឯកឧត្តម **ស៊ូ គីរិន្ទ** អភិបាលខេត្ត តាកែវ សមាជិក

៨-ឯកឧត្តម **រុង ផ្កាមកេសន** អភិបាលខេត្ត កោះកុង សមាជិក

៩-ឯកឧត្តម **អ៊ុង សាមី** អភិបាលខេត្ត បាត់ដំបង សមាជិក

១០-ឯកឧត្តម **ដួង ខេម** អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក

១១-ឯកឧត្តម **ទន់ ចាយ** អភិបាលខេត្ត សៀមរាប សមាជិក

១២-ឯកឧត្តម **ឈី ស៊ូ** អភិបាលខេត្ត ស្ទឹងត្រែង សមាជិក

១៣–ឯកឧត្តម **កែប ជុតិមា** អភិបាលខេត្ត រតនគីរី សមាជិក

១៤–ឯកឧត្តម **នូ ភឿន** អភិបាលខេត្ត ក្រចេះ សមាជិក

១៥–ឯកឧត្តម **ជុំ ឈឿន** អភិបាលខេត្ត មណ្ឌលគីរី សមាជិក

១៦–ឯកឧត្តម **គុណ គឹមគេង** អភិបាលខេត្ត កំពត សមាជិក

១៧–ឯកឧត្តម **មាន សារិន** អភិបាលខេត្ត ព្រះវិហារ សមាជិក

១៨–ឯកឧត្តម **ចក់ សារិក** អភិបាលខេត្ត កណ្ដាល សមាជិក

១៩–ឯកឧត្តម **រស់ ស្រេង** អភិបាលខេត្ត ពោធិសាត់ សមាជិក

២០–លោក **អ៊ាត លីហេង** អនុប្រធាននាយកដ្ឋានអាស៊ីនិង អូស្ត្រាលី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២១–លោក **ហួន សាវ៉ាង** អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

២២–លោក **លឹម វ៉ាន់** ប្រធានស្ដីទីនាយកដ្ឋានសុរិយោដី នៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

២៣–លោក **ម៉ែន អ៊ាន** ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

២៤–លោក **ជេត ខេមរា** មន្ត្រីនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ សមាជិក

២៥–លោក **ភូលិន្ទ មុណី** មន្ត្រីនាយកដ្ឋានអាស៊ីទទួលបន្ទុកវៀតណាម នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៦–លោក **ឌី សុផាន** អនុប្រធានទី ១ នាយកដ្ឋានកិច្ចការនយោបាយនៃក្រសួងមហាផ្ទៃ លេខាធិការ

**មាត្រា ២ :** គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះ មានខ្សែបណ្តាញជាភ្នាក់ងារកិច្ចការព្រំដែន រហូតដល់ខេត្ត និង ស្រុក ។

**មាត្រា ៣ :** គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន មានភារកិច្ចត្រួតពិនិត្យការពារបន្ទាត់ព្រំដែនក្នុងរយៈរង់ចាំការដោះស្រាយ ធ្វើអន្តរាគមន៍ដោះស្រាយ ចំពោះបាតុភាព ឬទំនាស់ព្រំដែនជាមួយខេត្តជាប់ព្រំដែនរបស់ប្រទេសជិតខាង និងចុះធ្វើការវាស់វែងបោះគោលបន្ទាត់ព្រំដែន តាមស្មារតីនៃលទ្ធផលដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។ ចូលរួមជាមួយគណៈកម្មាធិការនីតិកម្ម ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមការចាំបាច់ ។

**មាត្រា ៤ :** គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន មានលេខាធិការដ្ឋានជាជំនួយការរដ្ឋបាល និងសំរបសំរួលការងារដែលមានទីស្នាក់ការនៅក្រសួងមហាផ្ទៃ ។ គណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះ ជាផ្នែកមួយរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមានទីតាំងនៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខានៃលេខាធិការដ្ឋាននៃគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែននេះត្រូវជាសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការ ព្រំដែន ។ ក្នុងករណីចាំបាច់គណៈកម្មាធិការបច្ចេកទេសនេះអាចបង្កើតឬរៀបចំអនុគណៈកម្មការផ្សេង ៗ ដើម្បីសំរបសំរួលឬបំពេញភារកិច្ចរបស់គណៈកម្មាធិការបច្ចេកទេសនេះអោយមានប្រសិទ្ធភាព ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមអភិបាលខេត្តជាប់ព្រំដែន និងសាមីជនដែលមានឈ្មោះចែងក្នុងមាត្រា ១ ព្រមទាំងក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួល

អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២០ អនក្រ.បក**

**ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់**

**ក្រសួង និង រដ្ឋលេខាធិការដ្ឋាន**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- តាមតម្រូវការនៃការរៀបចំគ្រប់គ្រង និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង